# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:..៣៣....សសរ..

## សេចក្ដីសំរេច

## ស្ដីពី

## ការបង្កើតក្រុមការងារសំរាប់រៀបចំ និង ពិនិត្យ លើកិច្ចសន្យា ជួលដីឆ្នេរហាវ៉ៃ ទីក្រុងព្រះសីហនុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## <u>ស ំ រេ ច</u>

**<u>ប្រការ១</u>** : - ត្រូវបានបង្កើតក្រុមការងារសំរាប់រៀបចំ និង ពិនិត្យលើកិច្ចសន្យាជួលដីឆ្នេរហាវ៉ៃ ក្រុងព្រះសីហនុ អោយទៅក្រុមហ៊ុន Emario Shonan Marine Corporation ដើម្បីធ្វើការវិនិយោគវិស័យទេសចរណ៍ ហៅកាត់ថា "ក្រុមការងារ " ។

**<u>ប្រការ២</u>** : - ក្រុមការងារមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - តំណាង ទីស្ដីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| - តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - តំណាងក្រសួង រៀបចំដែនដី នគរូបនីយកម្ម និង សំណង់ | សមាជិក |
| - តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| - តំណាងក្រសួងទេសចរណ៍ | សមាជិក |
| - តំណាង ក្រសួងបរិស្ថាន | សមាជិក |
| - តំណាង រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | សមាជិក |
| - តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| - តំណាង សាលាក្រុងព្រះសីហនុ | សមាជិក |

**ប្រការ៣** : - ក្រុមការងារនេះមានភារកិច្ចដូចតទៅ :

- រៀបចំកិច្ចសន្យាជួលដីឆ្នេរហាវ៉ៃ ក្រុងព្រះសីហនុ
- ពិនិត្យ និង ចរចារលើថ្លៃឈ្នួលដីអោយបានសមស្រប
- ចុះពិនិត្យនិងវាស់វែងលើទីតាំង ភូមិសាស្ត្រតំបន់ដែលត្រូវជួល
- វាយតំលៃផលប៉ះពាល់ដល់បរិស្ថាន
- ពិនិត្យលើគំរោងសាងសង់របស់ក្រុមហ៊ុន អោយស្របតាមប្លង់នគរូបនីយកម្ម

**ប្រការ៤** : - សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៥** : - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួង សាធារណការ និង ដឹកជញ្ជូន ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងស្ថាប័នដទៃទៀតដែលមានឈ្មោះក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

**ចម្លងជូន:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ៥ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ